លីកាដូ

LICADHO

# ករណីរំលោភសេពសន្ថវៈ

# និង

# បៀតបៀនដល់កេរ្តិ៍ខ្មាស់ :

## ជាបទល្មើសព្រហ្មទណ្ឌនៅក្នុងសហគមន៍

របាយការណ៍ពិសេសរបស់អង្គការលីកាដូ

កុម្ភៈ ២០០១

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជាពិសេសចំពោះកញ្ញា **Mina Park** ក្នុងការជួយប្រមូល និង ចងក្រងពត៌មាននេះ ។ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅផងដែរចំពោះកញ្ញា **Christiana Brandt** ជាពិសេសបទសម្ភាសន៍របស់នាងជាមួយចៅក្រមខ្មែរ ម្យ៉ាងទៀតសូមថ្លែងអំណរគុណចំពោះ លោក-លោកស្រី និងអង្គការទាំងអស់ដែលបានចំណាយពេលវេលា និងផ្តល់ពត៌មាន និងសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះបុគ្គលិកអង្គការលីកាដូទាំងអស់ ជាពិសេសបុគ្គលិកផ្នែកស៊ើបអង្កេត ភ្នំពេញ-ខេត្តក្រុង ដែលបានផ្តល់នូវលទ្ធភាពគ្រប់បែបយ៉ាងក្នុងការរៀបចំរបាយការណ៍នេះ ។

អ្នកនិពន្ធ : **Diane O'Connell**

បោះពុម្ពផ្សាយ : សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស (លីកាដូ)
ខែ កុម្ភៈ ឆ្នាំ២០០១

អ្នកទំនាក់ទំនង : វេជ្ជ. **ពុង ឈីវកេក** ប្រធានអង្គការលីកាដូ

អាស័យដ្ឋាន : ផ្ទះលេខ ១០៣ ផ្លូវ ៩៧ សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន ភ្នំពេញ

ប្រអប់សំបុត្រ : **P.O Box 499** ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ/ទូរសារ : **(855) 023 360 965 / 364 901**

**E-mail** : **licadho@camnet.com.kh**

# របាយការណ៍ ស្តីពី ករណីរំលោភសេពសន្ថវៈ និង បៀតបៀនដល់កេរ្តិ៍ខ្មាស់

## អត្ថបទសង្ខេប

ក្នុងប្រទេសកម្ពុជា ចំនួនស្ត្រីនិងកុមារដែលរងគ្រោះខាងផ្លូវភេទ (រំលោភសេពសន្ថវៈ ឬអំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់) មានចំនួនកើនឡើងជារៀងរាល់ថ្ងៃ ។ ពួកគេមិនត្រឹមតែជាជនរងគ្រោះដោយសារបទល្មើសខាងផ្លូវភេទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាជនរងគ្រោះដោយអំពើហិង្សា ភាពអាម៉ាស់ និងរបួសផ្លូវកាយ ដោយអំពើទាំងនេះតែងតែកើតមានឡើងរួមគ្នាជាមួយបទល្មើសខាងផ្លូវភេទ ។ ពួកគេក៏ជាជនរងគ្រោះផ្លូវចិត្តដែរ ដែលបណ្តាលមកពីអំពើរំលោភសេពសន្ថវៈ ឬអំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់ ហើយភាពឈឺចាប់គឺមានជាប់ងំជាមួយពួកគេរាប់សិបឆ្នាំ អាចថាមួយជីវិត បើសិនជាគ្មានការជួយឧបត្ថម្ភ ឬការយល់អធ្យាស្រ័យនោះទេ ។

ជនរងគ្រោះពីអំពើរំលោភសេពសន្ថវៈដែលនៅមានជីវិតរស់នៅ តែងតែទទួលនូវការមាក់ងាយពីសង្គម ហើយសង្គមចាត់ទុកពួកគេជាស្រីខូច ។ ការមាក់ងាយពីសង្គមនិងភាពអាម៉ាស់ក្នុងគ្រួសារ គឺបណ្តាលមកពីការបាត់បង់ភាពក្រមុំព្រហ្មចារីយ៍ដោយសារអំពើរំលោភសេពសន្ថវៈនេះឯង ។ ជនរងគ្រោះមួយចំនួនយល់ឃើញថាមានតែការងារមួយទេដែលស័ក្តិសមជាមួយនឹងពួកគេ គឺប្រកបរបរជាស្រីពេស្យាចារ ។ មានឪពុកម្តាយមួយចំនួនថែមទាំងបានជំរុញអោយកូនស្រីខ្លួនឯងប្រកបរបរជាពេស្យាចារនេះ បើសិនជានាងមិនមានភាពក្រមុំព្រហ្មចារីយ៍តទៅទៀតនោះ ។ មានករណីផ្សេងទៀត ស្ត្រីជាជនរងគ្រោះត្រូវគេបង្ខំអោយរៀបការជាមួយបុរសដែលបានរំលោភខ្លួន ដើម្បីជាថ្នូរសំរាប់រក្សាកិត្តិយសគ្រួសារ ។

គ្មានជនណាម្នាក់ចង់អោយគេមករំលោភខ្លួនឡើយ ហើយក៏គ្មានជនណាម្នាក់មានសិទ្ធិទៅរំលោភអ្នកដទៃដែរ ។ អំពើរំលោភសេពសន្ថវៈ និងអំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់គឺជាអំពើហិង្សាដ៏ឃោរឃៅ ដែលជាទំរង់នៃភាពអយុត្តិធម៌តែងតែមានទៅលើស្ត្រីនិងកុមារដែលជាជនរងគ្រោះ ។ ជនរងគ្រោះតែងតែទទួលរងនូវភាពតក់ស្លុត និងភាពអាម៉ាស់មុខ ដូច្នេះពួកគេមានការស្ទាក់ស្ទើរក្នុងការពុះពារទៅមុខក្នុងការដាក់ពាក្យប្តឹងតទល់នឹងជនដែលបានរំលោភលើខ្លួន ។

មានពាក្យដោះសារមិនសមស្របរបស់បុរស ជាច្រើននៅក្នុងសង្គមដែលទាក់ទងទៅនឹងអំពើរំលោភសេពសន្ថវៈ ។ មានបុរសខ្មែរខ្លះពោលថា "បុរសមិនអាចគ្រប់គ្រងលើអារម្មណ៍ខ្លួនឯងបានឡើយ" ដូច្នេះគេមិនអាចបន្ទោសដោយសារអំពើដែលបានធ្វើដោយមោហ៍ បាំងបានទេ ។ យ៉ាងណាក៏ដោយអំពើរំលោភសេពសន្ថវៈគឺមិនមែនគ្រាន់តែជារឿងតណ្ហា ឬការរួមរ័ក្ស ប៉ុន្តែគឺជាការប្រើអំពើហិង្សា និងការបង្ខិតបង្ខំដោយកំលាំង ។ អំពើរំលោភសេពន្ថវៈដំបូងគឺសំដែងចេញនូវអំពើហិង្សា កំហឹង និងកំលាំងបង្ខិតបង្ខំក្នុងន័យធ្វើអោយឈឺចាប់ ក្តោបក្តាប់ស្ថានភាព និងធ្វើឱ្យអាម៉ាស់ដល់ជនរងគ្រោះ ។ មូលហេតុចំបងដែលជំរុញឱ្យមានអំពើរំលោភសេពសន្ថវៈ គឺជាការបញ្ចេញអារម្មណ៍នៃកំហឹង ការមើលងាយភាពងាយនឹងរងគ្រោះ ឬភាពមិនចេះឆ្អែតឆ្អន់ ។ អំពើរំលោភសេពសន្ថវៈពាក់ព័ន្ធទៅនឹងអំពើទារុណកម្មច្រើនជាងការរួមរក្ស័ ។ ពាក្យដោះសារអំពីអំពើរំលោភសេពសន្ថវៈ និងអំពើបៀតបៀនដល់ក្មេីខ្ចាស់ត្រូវតែលើកយកមកដោះស្រាយ និងបំបាត់ចោលតាមរយៈការអប់រំ និងផ្សព្វផ្សាយពត៌មានឱ្យបានជ្រួតជ្រាបទូទាំងប្រទេសកម្ពុជា ។

អំពើរំលោភសេពសន្ថវៈអាចមានផលវិបាកផ្លូវកាយយ៉ាងធ្ងន់ធ្ងរដល់ជនរងគ្រោះដោយរាប់ទាំងការឆ្លងជំងឺកាមរោគ និងជំងឺហ៊ីវ_អេដស៍ ព្រមទាំងផលវិបាកផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរផង។ ដោយសារជនរងគ្រោះជាច្រើនមិនបានទៅរាយការណ៍ពីអំពើរំលោភសេពសន្ថវៈ ដូច្នេះពួកគេប្រហែលជាមិនបានទទួលការព្យាបាលសុខភាព ឬការពិនិត្យជំងឺកាមរោគនោះទេ ។ ទោះបីជាមានអ្នកមកសុំអោយព្យាបាលក៏ដោយ ក៏សេវាកម្មផ្នែកព្យាបាលនិងចិត្តសាស្ត្រសំរាប់ជនរងគ្រោះពីការរំលោភផ្លូវភេទមិនទាន់មានគ្រប់គ្រាន់ឡើយ ។

អ្នកគាំទ្រមតិផ្នែកសិទ្ធិមនុស្សភាគច្រើនជឿថា អំពើរំលោភសេពសន្ថវៈនៅតាមសហគមន៍កំពុងតែកើនឡើង ហើយជនរងគ្រោះមានអាយុកាន់តែក្មេងទៅៗ ក៏ប៉ុន្តែមិនមានភស្តុតាងជាតួលេខដើម្បីបញ្ជាក់ពីមតិនេះទេ ។ មូលហេតុដែលផ្តោតចំពោះជំនឿដែលថាមានកំណើនកើនឡើងនៃបទល្មើសរំលោភសេពសន្ថវៈរួមមានស្ថានភាព និទណ្ឌភាព នៅក្នុងប្រទេសកម្ពុជា (ភាពគ្មានទោសពៃរ៍) កំណើននិងភាពងាយស្រួលក្នុងការប្រព្រឹត្តអំពើហិង្សា រូបអាសអាភាសជាក់ស្តែងភាពងាយរកគ្រឿនញៀន ដែលអាចយកមកប្រើដើម្បីធ្វើឱ្យជនរងគ្រោះបាត់បងស្មារតី ហើយនិងជំនឿរបស់បុរសនៅតំបន់អាស៊ីដែលថាការរួមរក្ស័ជាមួយស្រីក្រមុំព្រហ្មចារីយ៍

គឺធ្វើអោយមានប្រយោជន៍ដល់សុខភាព ។ ម្យ៉ាងទៀត ការរីករាលដាលនៃជំងឺ ហ៊ីវ-អេដស៍ ក្នុងប្រទេសកម្ពុជាបណ្តាលឱ្យបុរសមួយចំនួនស្វែងរកនារីកាន់តែក្មេងៗ ដើម្បីរួមរក្សព្រោះពួកគេជឿថាពួកគេនឹងចៀសផុតពីជំងឺ ។ ភរិយាខ្លះក៏បានជួយស្វាមីខ្លួនអោយរំលោភក្មេងស្រី ព្រោះពួកគេព្រួយបារម្ភពីការឆ្លងរោគហ៊ីវ-អេដ៍ បើសិនជាស្វាមីពួកគេទៅកាន់បនស្រី ឬមានស្រីកំណាន់ដែលមិនមានភាពបរិសុទ្ធ ។

មានភាពចាំបាច់បន្ទាន់មួយគឺត្រូវសិក្សាអំពីស្ថិតិ ដើម្បីកំណត់អំពីទំហំនៃអំពើរំលោភផ្លូវភេទ ដោយពិតប្រាកដក្នុងប្រទេសកម្ពុជា ហើយផ្ទៀងផ្ទាត់ថា តើអំពើរំលោភនោះកំពុងកើនឡើង ឬយ៉ាងណា ។ ទោះជាយ៉ាងណាក៏ដោយអំពើរំលោភទាំងនោះបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា អំពើរំលោភផ្លូវភេទនិងបៀតបៀនកេ្តីខ្មាស់ គឺកើតមានជាទូទៅក្នុងសហគមន៍ហើយដំណោះស្រាយលើបញ្ហានោះមានតិចតួចណាស់ទាំងការការពារ ទប់ស្កាត់ក្តី ឬការស្តារនីតិសម្បទាសំរាប់ជនរងគ្រោះក្តី។

អំពើល្មើសផ្លូវភេទធ្វើឱ្យរងគ្រោះបន្តបន្ទាប់ ដំបូងរងគ្រោះដោយសារជនល្មើស ឬជនដលចាប់គេរំលោភ ហើយបន្ទាប់មកគឺរងគ្រោះដោយសារសង្គម ជំនឿជាប្រពៃណីពីតួនាទីរបស់ស្ត្រីនៅក្នុងសង្គម និងសារៈសំខាន់ដែលមានចំពោះស្ត្រីក្រមុំព្រហ្មចារីយ៍ជំរុញឱ្យនរងគ្រោះនិងគ្រួសារមានអារម្មណ៍កាន់តែអាម៉ាស់ ដែលអាចបណ្តាលឱ្យមានរហូតដល់ធ្វើអត្តឃាតខ្លួនឯងណ្តាលឱ្យមានវាយដំពីសំណាក់គ្រួសារទៅលើជនរងគ្រោះ ការនិយាយឡុកឡឺយពីសំណាក់អ្នកភូមិ ការយាយីជាបន្តបន្ទាប់ពីសំណាក់ជនល្មើស ឬក្រុមគ្រួសាររបស់ជនល្មើស ព្រមទាំងការចុះទ្រុឌទ្រោមយ៉ាងធ្ងន់ធ្ងរទាំងខាងផ្លូវកាយនិងផ្លូវចិត្ត ។ អំពើរំលោភសេពសន្ថវៈបន្សល់នូវស្លាកស្នាមដ៏ជូរចត់ក្នុងជីវិតជនរងគ្រោះជារៀងរហូត ចំណែកជនល្មើសភាគច្រើនមិនដែលត្រូវបាននាំខ្លួនមកកាន់តុលាការម្តងណាឡើយ ហើយក្នុងចំណោមជនល្មើសដែលបាននាំខ្លួនមកកាន់តុលាការនោះ ជនល្មើសជាច្រើនមិនដែលទទួលការផ្តន្ទាទោសសមស្របតាមច្បាប់ឡើយ ។

ការឱ្យតម្លៃយ៉ាងខ្ពស់ចំពោះភាពក្រមុំព្រហ្មចារីយ៍នៅប្រទេសកម្ពុជា បង្កឱ្យមានអំពើហិង្សាសេពកាមជាច្រើនកំរិត ។ ភាពអាម៉ាស់ ការបាត់បង់ភាពក្រមុំបរិសុទ្ធតែងតែក្លាយជាចំណុចសំខាន់នៃអំពើរំលោភសេពសន្ថវៈ ដោយប្តូរការយកចិត្តទុកដាក់ពីជនប្រព្រឹត្តបទល្មើស

និង អំពើព្រៃផ្សៃខុសច្បាប់របស់ជននោះតែបែរជាយកចិត្តទុកដាក់ទៅលើនារីរងគ្រោះ និង បញ្ហាបាត់បង់គុណធម៌របស់នាងទៅវិញ។ ឥរិយាបទសង្គម ទ្រឹស្ដីអំពីអំពើរំលោភសេពសន្ថវៈ និង តួនាទីជាប្រពៃណីរបស់ស្ត្រីមានឥទ្ធិពលលើចៅក្រមក្នុងការកាត់ក្ដីបទរំលោភសេពសន្ថវៈ ជាពិសេសវិធីដែលគេបកស្រាយកោសល្យវិច្ច័យពេទ្យ តែងតែធ្វើអោយខូចប្រយោជន៍ជនរងគ្រោះ ។ ភស្ដុតាងចាំបាច់ក្នុងបទល្មើសរំលោភសេពសន្ថវៈសំរាប់យកទៅបង្ហាញក្នុងពេលសវនាការ គឺលិខិតកោសល្យវិច្ច័យពេទ្យស្ដីពីការពិនិត្យសុខភាពរបស់ជនរងគ្រោះធ្វើឡើងនាពេលណាមួយក្រោយពីការរំលោភសេពសន្ថវៈ ដែលជាញឹកញាប់ធ្វើឱ្យជនរងគ្រោះនោះមិនប្រាប់អ្នកណាម្នាក់ ឬស្វែងរកសេវាថែទាំសុខភាពបានភ្លាមៗនោះទេ ។ ពត៌មានដែលមាននៅក្នុងលិខិតកោសល្យវិច្ច័យពេទ្យជារឿយៗមានលក្ខណៈមិនគ្រប់គ្រាន់សោះឡើយ។

នៅពេលពិនិត្យលើលិខិតកោសល្យវិច្ច័យពេទ្យ ចៅក្រមតែងតែស្វែងរកភស្ដុតាងរបួសធ្ងន់ធ្ងរនៅលើប្រដាប់បន្ដពូជរបស់នារីរងគ្រោះ ដើម្បីបង្ហាញថាការរួមរក្ស័នោះកើតមានឡើងដោយគ្មានការព្រមព្រៀងគ្នា ។ ចៅក្រមខ្លះយល់ថា ការដែលមិនមានរបួសនៅលើប្រដាប់បន្ដពូជរបស់នារីរងគ្រោះ មានន័យថា ការរួមរក្ស័នោះគឺធ្វើឡើងដោយមានការព្រមព្រៀងគ្នា ហើយវាមិនមែនជាអំពើរំលោភសេពសន្ថវៈនោះទេ ។ ក៏ប៉ុន្តែ ការសិក្សាស្រាវជ្រាវនៅសហរដ្ឋអាមេរិកបានបញ្ជាក់ថា អំពីរំលោភសេពសន្ថវៈភាគច្រើនរួមទាំងអំពើដែលមានការប្រតាយប្រតប់គ្នាខ្លាំងផង មិនមានបន្សល់ទុកស្លាកស្នាម ដាច់ រហែក មុត ឬ ស្លាកស្នាមលើរាងកាយ ឬលើអង្គជាតិស្ត្រីឡើយ ។ អំពើរំលោភសេពសន្ថវៈជាច្រើននៅប្រទេសកម្ពុជាបានធ្វើឡើងដោយប្រើអាវុធ ការគំរាមកំហែងប្រើហិង្សា ឬសំលាប់ចោល ដូច្នេះនារីរងគ្រោះជាច្រើនមិនបានប្រតាយប្រតប់ ឬប្រឆាំងតបតវិញសោះឡើយ ដូច្នេះអាចថាសឹងតែមិនមានស្លាកស្នាមរបួសរាងកាយ អញ្ចឹងហើយចៅក្រមសឹងតែមិនបានគិតថា ការរួមរក្ស័នោះបានកើតឡើងដោយគ្មានការព្រមព្រៀងគ្នានោះទេ ។

រឿងក្ដីរំលោភសេពសន្ថវៈជាច្រើន មិនបានយកទៅដោះស្រាយបញ្ចប់តាមផ្លូវតុលាការនោះទេ ។ រឿងក្ដីបែបនេះជាច្រើនត្រូវបានដោះស្រាយបញ្ចប់ដោយការព្រមព្រៀងបង់លុយអោយជនរងគ្រោះ និង/ឬ គ្រួសារជនរងគ្រោះ ដោយជនល្មើសជាជាងការផ្ដន្ទាទោសតាមច្បាប់ ។ ជាញឹកញាប់ ប៉ូលីស ឬបុគ្គលិកតុលាការតែងមានការពាក់ព័ន្ធនៅក្នុងការផ្សះផ្សា

រឿងក្តីតាមរយៈការបង់ប្រាក់ឱ្យនារីរងគ្រោះ ដោយពួកខ្លួនបានទទួលកម្រៃខ្លះផងជាជាងអ្នកទាំងនេះអនុវត្តកាតព្វកិច្ចតាមផ្លូវច្បាប់របស់ពួកខ្លួន ក្នុងការស៊ើបអង្កេតនិងផ្តន្ទាទោសបទឧក្រិដ្ឋធ្ងន់ធ្ងរទាំងនោះ ។

រឿងក្តីរំលោភសេពសន្ថវៈនិងអំពើបៀតបៀនក្មេងខ្ចាស់ ដែលអង្កេតដោយ LICADHO ពីខែ មករា ឆ្នាំ ១៩៩៩ មកដល់ខែ មិនា ឆ្នាំ២០០០ បង្ហាញថា មានរឿងក្តីតែ ៥១ % ទេ ដែលបានដោះស្រាយតាមវិធីខ្លះ(ស្របច្បាប់ ឬតាមវិធីផ្សេងៗ)ហើយដែលឥឡូវនេះ រឿងក្តីទាំងនេះបានបំបិទចោល ។ ក្នុងចំណោមរឿងក្តីដែលបានបំបិទទាំងនេះមានរឿងក្តី ៤១ % ដែលបានផ្សះផ្សាតាមរយៈការព្រមព្រៀងបង់ប្រាក់ ។ ក្នុងរឿងក្តីដែលមិនទាន់បានដោះស្រាយចប់ដែលមានរហូតដល់សព្វថ្ងៃនេះមានរឿងក្តី ២៦ % ដែលជនល្មើសបានគេចខ្លួនរួច ហើយរឿងក្តីឯទៀតស្ថិតនៅក្រោមការស៊ើបអង្កេត ឬ រង់ចាំថ្ងៃបើកសវនាការ បន្ទាប់ពីបទល្មើសនេះបានកើតមានឡើងអស់រយៈពេលមួយ ឬពីរឆ្នាំកន្លងមកហើយ ។

ទាំងច្បាប់អន្តរជាតិនិងច្បាប់ក្នុងស្រុកទប់ស្កាត់អំពើល្មើសផ្លូវភេទ ក៏ប៉ុន្តែរឿងនេះមានន័យតិចតួចបំផុតសំរាប់ជនរងគ្រោះពីបទល្មើសរំលោភសេពសន្ថវៈ និង អំពើបៀតបៀនក្មេងខ្ចាស់ ។ ច្បាប់ដែលកំពុងអនុវត្តក្នុងប្រទេសកម្ពុជាពីបទរំលោភសេពសន្ថវៈ និងអំពើបៀតបៀនក្មេងខ្ចាស់ គឺមិនមានលក្ខណៈគ្រប់គ្រាន់ ជាពិសេសចំពោះអនីតិជន ហើយអនុវត្តបានតិចតួចបំផុត ។ កុមារមិនត្រូវបានការពារសោះឡើយ ដោយហេតុថាច្បាប់មិនបានចែងពីអនីតិជនទាក់ទិននឹងបទល្មើស ច្បាប់មិនបានកំណត់អោយបានច្បាស់ពីអាយុស្របច្បាប់ដើម្បីរួមភេទ ហើយច្បាប់ក៏មិនមានបញ្ញត្តិអំពីការរំលោភសេពកាមដែរ។

ក្រមព្រហ្មទណ្ឌថ្មី គឺកំពុងតែព្រាង ហើយមានក្រមព្រហ្មទណ្ឌ២ផ្សេងគ្នា ដែលត្រូវបានគេរាយការណ៍ថាបានតាក់តែងឡើង ។ ក្រមព្រហ្មទណ្ឌទី១ ដែលព្រាងជាខេមរភាសាមិនត្រឹមតែមិនបានដោះស្រាយគុណវិបត្តិដែលទាក់ទងនឹងអំពើរំលោភសេពសន្ថវៈ និងអំពើបៀតបៀនក្មេងខ្ចាស់ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងបង្កើតឱ្យមានបញ្ហាកាន់តែច្រើនឡើងផង ។ ក្រមព្រហ្មទណ្ឌទី២ ដែលព្រាងជាភាសាបារាំងមានប្រហែល ៨០០មាត្រា ហើយមិនទាន់បានបកប្រែទៅជាខេមរភាសា ឬជាភាសាអង់គ្លេសនៅឡើយទេ ។ ការសំខាន់ឱកាសដើម្បីធ្វើអោយ

ច្បាប់ព្រហ្មទណ្ឌល្អប្រសើរឡើងក្នុងករណីទាក់ទងនឹងអំពើល្មើសផ្លូវភេទ ដោយការបង្កើតក្រម ព្រហ្មទណ្ឌថ្មីមិនមែនជាការខ្ជះខ្ជាយឥតប្រយោជន៍នោះទេ ។ ក្រមថ្មីត្រូវលើកយកមកដោះ ស្រាយនូវការខ្វះចន្លោះជាច្រើនដែលមាននៅក្នុងច្បាប់បច្ចុប្បន្ន ហើយត្រូវព្រាងជាចំហ និង ដាក់ជូនសាធារណៈជូនពិភាក្សា ។ ក្រមដែលព្រាងជាខេមរភាសា ហើយដែលបច្ចុប្បន្នកំពុង តែចែកចាយ មានលក្ខណៈមិនគ្រប់គ្រាន់ ហើយមិនអាចទទួលយកបានឡើយ។

គំលាតរវាងច្បាប់និងការអនុវត្តន៍ច្បាប់នៅប្រទេសកម្ពុជា គេបានដឹងច្បាស់ណាស់ ហើយគេកំពុងតែចងក្រងពីបញ្ហានេះ ។ ចំពោះរឿងក្ដីដែលអង្គការ LICADHO បានធ្វើការ អង្កេតមានភស្តុតាងជាច្រើនស្ដីពីការខកខានរបស់ប៉ូលីស និងតុលាការក្នុងការប្រតិបត្តិច្បាប់ ក្នុងការផ្ដន្ទាទោសជនជាប់ចោទ និងផ្ដល់យុត្តិធម៌ដល់ជនរងគ្រោះ ។ ជាចំបងបញ្ហានេះ បណ្ដាលមកពីអំពើពុករលួយព្រោះថា "លុយងាយ" អាចបានមកពីទុក្ខសោករបស់នារីរងគ្រោះ ដែលត្រូវគេរំលោភ ។ កត្តាសំខាន់មួយទៀតគឺថាអាជ្ញាធរពុំមានទស្សនៈថាអំពើរំលោភផ្លូវ ភេទគឺជាបទល្មើសធ្ងន់ធ្ងរនោះទេ ។

ជាញឹកញាប់ វិធីដែលចៅក្រមអនុវត្តច្បាប់ គឺមានលក្ខណៈមិនត្រឹមត្រូវ និងមិនទៀង ទាត់។ ចៅក្រមអនុវត្តន៍ច្បាប់តាមវិធីមួយដែលប្រសើរបំផុតដើម្បីឱ្យត្រូវទៅនឹងផលប្រយោជន៍ របស់ពួកគេជាញឹកញាប់ គឺការបង់ប្រាក់ធ្វើឡើងដោយជនជាប់ចោទ ដើម្បីទទួលនូវសាល ក្រមគ្មានទោស ឬក៏ការព្យួរទោស ។ រឿងនេះអនុញ្ញាតឱ្យមានការដោះសារចំពោះសេចក្ដី សំរេចរបស់ចៅក្រមដែលមិនត្រឹមត្រូវតាមច្បាប់ ហើយអាចឱ្យជនល្មើសដែលបានប្រព្រឹត្ត បទល្មើសរំលោភផ្លូវភេទធ្ងន់ធ្ងរ ទទួលការផ្ដន្ទាទោសតិចតួចប៉ុណ្ណោះ ខ្លះអត់សោះក៏មាន ។ ឧទាហរណ៍ មួយស្ដីពីការពន្យល់ហេតុផលបែបនេះដែលមានដក់យ៉ាងជ្រៅក្នុងគំនិតរបស់ ចៅក្រមនោះគឺថា ប្រសិនបើជនរងគ្រោះមិនមានរបួសធ្ងន់ធ្ងរនៅកន្លែងអង្គជាតិរបស់នាងទេ អញ្ចឹងលិង្គរបស់បុរសមិនទាន់បានចូលឱ្យជ្រៅល្មមទៅក្នុងអង្គជាតិរបស់ស្ត្រី ដើម្បីចាត់ថា ជាការរំលោភនោះទេ ដូច្នេះចៅក្រមសំរេចប្ដូរការចោទប្រកាន់ពីបទរំលោភសេពសន្ថវៈដែល ជាបទឧក្រិដ្ឋ ទៅជាបទអំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់ដែលជាបទមជ្ឈឹមវិញ ។ ការសំរេចដូច នេះគឺមិនត្រឹមត្រូវទេ ព្រោះការបញ្ចូលអង្គជាតិរបស់បុរស (ជ្រៅក៏ដោយមិនជ្រៅក៏ដោយ) ក៏ច្បាប់បានកំណត់ថាអំពើនេះគឺជាអំពើរំលោភសេពសន្ថវៈ ។ ការផ្ដន្ទាទោសស្រាលពីបទ

មជ្ឈឹមស្តីពីអំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់ ពិតជាអនុញ្ញាតឱ្យចៅក្រមសំរេចព្យួរទោសបានមានន័យថាជនល្មើសអាចទទួលទោសតិចតួចបំផុត ឬមួយថាមិនជាប់ពន្ធនាគារសោះក៏ថាបាន ។ ក្នុងករណីបែបនេះគេតែងតែសង្ស័យថាប្រាក់ដែលជនល្មើសបានបង់ គឺជាមូលហេតុជាក់ស្តែងដែលនាំឱ្យចៅក្រមសំរេចបន្ថយការចោទប្រកាន់ ។ អំពើពុករលួយនិងការមិនគោរពច្បាប់បែបនេះធ្វើឱ្យមានការដោះសារមិនសមស្របជារៀងរហូតថា អំពើហិង្សាប្រឆាំងនឹងស្ត្រីភេទមិនមែនជាបទល្មើសធ្ងន់ធ្ងរនោះទេ ។

អាជ្ញាធរបំពានច្បាប់ ដោយខកខានមិនបានបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់របស់ពួកគេក្នុងការស៊ើបអង្កេត និងផ្តន្ទាទោសបទល្មើស ។ ដោយអនុញ្ញាតឱ្យឧក្រិដ្ឋកម្មទាំងនេះប្រព្រឹត្តទៅដោយមិនបានផ្តន្ទាទោស ធ្វើឱ្យស្ថានភាពស្តីពីការមិនដាក់ទោសដល់ឧក្រិដ្ឋជនមានជានិរន្តរ៍នៅប្រទេសកម្ពុជា ហើយបង្កឱ្យមានការវិលចុះវិលឡើងនៃអំពើហិង្សាដែលធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍន៍ប្រទេសជាច្រើនទសវត្សមកហើយ ។

អំពើរំលោភសេពសន្ថវៈ និងអំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់ គឺជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរហើយការចាត់ទុកឧក្រិដ្ឋកម្មទាំងនេះតាមរបៀបមិនសមស្របណាមួយនោះ ពិតជាបន្ថយទម្ងន់ទោសនៃអំពើល្មើសផ្លូវភេទនេះ ហើយនឹងផលប៉ះពាល់ពីឧក្រិដ្ឋកម្មទាំងនេះមានចំពោះនារីរងគ្រោះនិងចំពោះគ្រប់ស្រទាប់សង្គមទាំងអស់ ។ ការយល់ព្រមរបស់សង្គមចំពោះការបង់ប្រាក់បែបនេះថាជាទម្រង់យុត្តិធម៌គឺការអនុវត្តន៍នីតិរដ្ឋនៅប្រទេសកម្ពុជា ដែលប្រជាពលរដ្ឋមានទំនុកចិត្ត ហើយដែលសព្វថ្ងៃនេះពួកគេគ្មានទំនុកចិត្តបែបនេះឡើយ ។ ដើម្បីបង្កើនទំនុកចិត្តអំពើពុករលួយក្នុងជួរប៉ូលីស និងតុលាការត្រូវតែលើកយកមកដោះស្រាយ ហើយជនល្មើសត្រូវតែទទួលនូវការផ្តន្ទាទោសឱ្យសមល្មមតាមបញ្ញត្តិច្បាប់ ។

ប៉ូលីសនិងតុលាការបានទទួលការអប់រំបណ្តុះបណ្តាលតិចតួចណាស់ ព្រមទាំងទទួលបានថវិកាយ៉ាងតិចតួចសំរាប់ចាត់ចែងនាយកដ្ឋានរបស់ខ្លួន ។ អំពើពុករលួយត្រូវបានអធ្យាស្រ័យដោយរដ្ឋាភិបាល ហើយរហូតដល់ទៅលើកទឹកចិត្តឱ្យមានទៀតផង ដោយសារតែប្រាក់បៀវត្សដែលបានទទួលពីរដ្ឋភិបាលធ្វើឱ្យបុគ្គលិករដ្ឋមានការជ្រើសរើសតិចតួចណាស់ដើម្បីអាចឱ្យមានជីវភាពសមរម្យបាន ក្រៅពីស្វែងរកមធ្យោបាយផ្សេងទៀត ។ កង្វះនៃការអនុវត្តន៍ច្បាប់

និងអំពើពុករលួយគឺឋិតនៅជានិច្ចកាលក្នុងផ្នត់គំនិតនៃអំពើរំលោភភេទ (និងបទល្មើសដទៃទៀត) នៅប្រទេសកម្ពុជា ។ វាអាស្រ័យលើរដ្ឋាភិបាលក្នុងការពង្រឹងប្រព័ន្ធច្បាប់ ប៉ុន្តែមកដល់ថ្ងៃនេះឆន្ទៈរបស់រដ្ឋាភិបាលក្នុងការពង្រឹងច្បាប់គឺមានកំរិតតិចតួចបំផុត ។

ថ្វីបើបទល្មើសផ្លូវភេទកើតមានឡើងគ្រប់អាយុនិងភេទទាំងអស់នៅប្រទេសកម្ពុជា ក៏ដោយ ក៏យុវវ័យនៅកម្ពុជាគឺជាជនរងគ្រោះខ្លាំងជាងគេ ហើយកាន់តែទទួលរងក្នុងស្ថានភាពជាជនរងគ្រោះនិងជាអ្នកប្រព្រឹត្តបទល្មើស ។ ក្នុងចំណោមបទល្មើសផ្លូវភេទដែលអង្គការលីកាដូ បានអង្កេតរវាងខែ មករា ឆ្នាំ១៩៩៩ មកដល់ខែមិនា ឆ្នាំ២០០០ មានជនជាប់សង្ស័យចំនួន ៧% ដែលមានអាយុក្រោម ១៦ឆ្នាំ ដែលជាតួលេខគួរឱ្យចាប់អារម្មណ៍ ជាពិសេសដោយសារកង្វះសម្ភារៈសំរាប់ធ្វើឱ្យមាននីតិសម្បទាឡើងវិញ ចំពោះជនល្មើសផ្លូវភេទនៅប្រទេសកម្ពុជា ។ គេបានទទួលស្គាល់នៅទូទាំងពិភពលោកថា អំពើល្មើសផ្លូវភេទបានធ្វើឱ្យមានផលវិបាកផ្លូវចិត្តយ៉ាងខ្លាំងទៅលើជនរងគ្រោះ ហើយប៉ះពាល់មួយកំរិតដែរចំពោះជនណាដែលបានឃើញអំពើនេះ ។ ជាញឹកញាប់វដ្តនៃការរំលោភបំពានត្រូវបានបង្កើតឡើងដែលជនរងគ្រោះអាចក្លាយទៅជាអ្នកបំពានវិញម្តង ឬស្ថិតនៅតែជាជនរងគ្រោះអស់មួយជីវិត ។ ដោយបានដឹងពីចំនួនយុវជនកម្ពុជាដែលទទួលរងគ្រោះដោយឧក្រិដ្ឋកម្មផ្លូវភេទនោះ នឹងមានការព្រួយបារម្ភយ៉ាងខ្លាំងនាពេលខាងមុខ ចំពោះបញ្ហាសុខភាពក្នុងសង្គមនៅប្រទេសកម្ពុជា។

ប្រទេសកម្ពុជាមានស្ថានភាពអន់ថយក្នុងការដោះស្រាយផលវិបាកយ៉ាងធ្ងន់ធ្ងរជាច្រើនស្តីពីអំពើល្មើសផ្លូវភេទ ទាំងចំពោះមុខបុគ្គលជាជនរងគ្រោះ និងចំពោះមុខសង្គមទាំងមូល ។ ការព្យាបាលមិនបានដិតដល់ចំពោះហេតុប៉ះពាល់ទាំងផ្នែកផ្លូវកាយនិងផ្លូវចិត្ត ទៅលើជនរងគ្រោះនៃបទល្មើសផ្លូវភេទ គឺជាបញ្ហាធ្ងន់ធ្ងរដែលត្រូវលើកយកមកដោះស្រាយ ។

ផលវិបាកខាងផ្លូវកាយដែលបណ្តាលមកពីបទល្មើសរំលោភសេពសន្ថវៈ អាចរាប់ទាំងរបួសដែលបានទទួលរងនៅពេលប្រព្រឹត្តបទល្មើស គឺឈឺផ្ទៃពោះ ឈឺផ្សានៅកន្លែងអង្គជាតិស្ត្រី ការឆ្លងជំងឺកាមរោគ រួមទាំងការព្រួយបារម្ភក្នុងជីវិតពីការឆ្លងមេរោគហ៊ីវ ។ ដោយហេតុថាជនរងគ្រោះជាច្រើនមិនបានរាយការណ៍ពីអំពើរំលោភដែលមានមកលើខ្លួន ជនរងគ្រោះជាច្រើនមិនបានទទួលការថែទាំសុខភាពឱ្យបានគ្រប់គ្រាន់ ឬការបង្ការរោគ ជាពិសេស

ការធ្វើតេស្ត ហ៊ីវ_អេដស៍ ឬជំងឺកាមរោគផ្សេងៗ ។ ម្យ៉ាងទៀតជនរងគ្រោះជាច្រើនមិនបាន ទទួលនូវការថែទាំសុខភាពសមរម្យដោយសារបញ្ហាថវិកា ឬបញ្ហាទីកន្លែងរស់នៅ ។

បញ្ហាផ្លូវចិត្តដែលបណ្តាលមកពីអំពើរំលោភសេពសន្ថវៈ និងអំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់អាចធ្វើឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ជនរងគ្រោះ ជាពិសេសក្នុងរយៈពេលយូរ ។ ជាបែបផែនរោគសញ្ញាដែលជនរងគ្រោះទទួលរង រួមមានការថប់អារម្មណ៍យ៉ាងខ្លាំង ពិរុទ្ធភាព ភាពកណ្តោចកណ្តែង ការថយកំលាំងកាយឬចិត្ត កង្វះទំនុកចិត្ត ភាពរ៉ាំរ៉ៃ ការបង្កអធិករណ៍ ការធ្វើកាយវិកលកម្មខ្លួនឯង ការធ្វើអត្តឃាត ភាពភ័យខ្លាច ភាពអាម៉ាស់មុខ ភាពអៀនខ្មាស់ ភាពស្មុគស្មាញក្នុងចិត្ត ការស្តីបន្ទោសឱ្យខ្លួនឯង ការអស់សង្ឃឹម ការបាត់បង់រសជាតិអាហារ ដំណើរចង់ក្អួត ការឈឺក្បាលធ្ងន់ធ្ងរ និងការអស់កំលាំង ។

ថ្វីបើមានកម្មវិធីប្រឹក្សាយោបល់ផ្លូវចិត្តដ៏មានប្រសិទ្ធិភាពក៏ដោយ ជាពិសេសនៅទីក្រុងភ្នំពេញក៏ជនរងគ្រោះភាគច្រើនមិនបានទទួលការប្រឹក្សាយោបល់ណាមួយ ជាពិសេសនៅក្នុងខេត្តនានា ។ ចំពោះជនរងគ្រោះដែលជាអនីតិជន និង ជនរងគ្រោះដែលមានអាយុលើស១៨ឆ្នាំ មានសេវាប្រឹក្សាយោបល់តិចតួចណាស់ដែលអាចជ្រើសរើសបាន ។ មានការខ្វះខាតយ៉ាងខ្លាំងនូវមនុស្សដែលមានគុណវុឌ្ឍិដែលអាចធ្វើឱ្យជនរងគ្រោះស្បើយពីទុក្ខសោកបណ្តាលមកពីការរំលោភផ្លូវភេទនេះ ។

ថ្វីបើមានការទទួលស្គាល់ផ្ទាល់ខ្លួន ថាការរំលោភផ្លូវភេទជាបញ្ហាធ្ងន់ធ្ងរក៏ដោយ ក៏សាធារណជនធ្វើមិនដឹងមិនឮចំពោះអំពើនេះដែរ។ ការទំលុះភាពស្ងាត់ស្ងៀមគឺជាកត្តាសំខាន់ចាំបាច់ ប្រសិនបើចង់លើកយកមកដោះស្រាយនូវបញ្ហា ដែលកើតមានពីការរំលោភផ្លូវភេទ ។ ការកែប្រែឥរិយាបទសង្គមស្តីពីការរំលោភផ្លូវភេទ និងជនរងគ្រោះនៃអំពើនេះត្រូវការរយៈពេលយ៉ាងយូរ ហើយអាចធ្វើឱ្យសំរេចបានគឺតាមរយៈការអប់រំតែប៉ុណ្ណោះ ។ កម្មវិធីការពារគឺជាកត្តាសំខាន់ ចាំបាច់ ជាពិសេសត្រូវការកម្មវិធីណាដែលផ្តោតទៅលើការរំលោភផ្លូវភេទតែមួយមុខប៉ុណ្ណោះ ។ អំពើរំលោភសេពសន្ថវៈនៅតាមសហគមន៍គឺជាបញ្ហាតែមួយគត់ដែលតម្រូវឱ្យមានការផ្តើមដោះស្រាយតែមួយមុខដែរ ។

ថ្វីបើការអប់រំបណ្តុះបណ្តាលអំពីការស៊ើបអង្កេតលើអំពើល្មើសផ្លូវភេទត្រូវកំរិតត្រឹម ប៉ូលីស និងអាជ្ញាធរដែនដីក៏ដោយ ក៏ស្ទើរតែមិនមានការហ្វឹកហ្វឺនផ្នែកតុលាការនៅក្នុងវិស័យនេះដែរ ។ ដូចគ្នានេះដែរមានតំរូវការជាបន្ទាន់ក្នុងការហ្វឹកហ្វឺនបុគ្គលិកសុខាភិបាលអំពីការផ្តល់សេវាថែទាំសុខភាពសមរម្យដល់ជនរងគ្រោះពីការរំលោភផ្លូវភេទ ។ វាក៏ជាការចាំបាច់ដែរថា ការពង្រឹងកិច្ចសហការរវាងអង្គការជាតិ អង្គការក្រៅរដ្ឋាភិបាល អាជ្ញាធរដែនដី និងរាជរដ្ឋាភិបាលត្រូវតែចាប់ផ្តើមភ្លាម ប្រសិនបើគេចង់លើកយកមកដោះស្រាយនូវអំពើរំលោភសេពសន្ថវៈ និងអំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់ដែលរាតត្បាតនៅប្រទេសកម្ពុជា ។